គ្រួសារសិស្សានុសិស្សក្នុងក្រសួងអប់រំតំបន់ឡុងប៊ីចជាទីមេត្រី

សូមអរគុណដល់វិធានការណ៏ដែលលោកអ្នកកំពុងធ្វើដើម្បីថែរក្សាកូននិងសមាជិកក្រុមគ្រួសាររបស់លោកអ្នកនៅក្នុងពេលមានការបារម្មណ៍ពីសុខភាពនៅក្នុងសហគមន៍យើងនិងនៅជុំវិញពិភពលោក។ យើងកំពុងធ្វើគ្រប់ យ៉ាងដើម្បីកាត់បន្ថយការឆ្លងរាលដាលនូវវីរុសកូរ៉ូណាថ្មីនេះ ព្រមទាំងកំពុងរៀបត្រៀមបំរុងសម្រាប់ការប្រតិបត្តិភ្លាមៗ ដើម្បីប្រឈមមុខនឹងរឿងហេតុអ្វីមួយដែលទាក់ទងទៅនឹងសិស្សនិងក្រុមគ្រួសាររបស់គេ។

ការខ្នះខ្នែងរបស់យើងនៅសប្តាហ៍នេះមានរួមទាំងការជូតសម្អាតសម្លាប់មេរោគនៅកន្លែងណាដែលមានការប៉ះពាល់ច្រើនជាមួយនឹងទឹកថ្នាំសម្លាប់មេរោគ ការរំលឹកពីការចាំបាច់ទុកកូននៅផ្ទះបើសិនជាគាត់មានរោគសញ្ញាគ្រុនផ្តាសាយ ពង្រឹងការបន្តនូវភាពប្រុងប្រយ័ត្ន ជាពិសេសការលាងដៃ សម្រាប់អនុវត្តដោយសិស្ស ក្រុមគ្រួសារ និងបុគ្គលិកសាលាទាំងអស់។ នៅក្នុងសប្តាហ៍ខាងមុខនេះ គ្រប់សាលារៀននឹងមានបុគ្គលិកអនាម័យធ្វើការលាងសម្អាតសម្លាប់មេរោគបន្ថែមទៀត។

ក្រសួងអប់រំ LBUSD មានបុគ្គលិកជំនាញច្រើននាក់និងមាននាយកដ្ឋានផ្សេងៗ ដែលត្រូវបានចាត់តាំងឱយធ្វើការសម្រេចចិត្ត ស្តីអំពីវីរុសកូរ៉ណា ហើយពួកគេកំពុងធ្វើទំនាក់ទំនងយ៉ាងសកម្មជាមួយបុគ្គលិកក្រសួងសុខាភិបាលឡុងប៊ីច។ បុគ្គលិកក្រសួងសុខាភិបាលឡុងប៊ីចត្រៀមបំរុងពិភាក្សាជាមួយយើងអំពីសេចក្តីបារម្មណ៍ទាំងឡាយដែលបានកើតមានឡើង ដើម្បីផ្តល់នូវការណែនាំផ្សេងៗនៅក្នុងការសំរេចចិត្តរបស់យើង ហើយដើម្បីចែករំលែកនូវព័ត៌មានពិតៗទាក់ទងទៅនឹងហានិភ័យក្នុងសហគមន៍យើង។

គេហទំព័រក្រសួងអប់រំនៅ lbschools.net មានដាក់ផ្សាយនូវសំណួរនិងចម្លើយពីបញ្ហាវីរុសកូរ៉ូណានេះ យោងតាមការស្នង់មតិពីមាតាបិតា បុគ្គលិក និងសមាជិកក្នុងសហគម។ សំណួរនិងសម្លើយនេះនឹងត្រូវធ្វើបច្ចុប្បន្នភាពជាមួយសំណួរនិងព័ត៌មានថ្មីៗជាញឹកញាប់។

បច្ចុប្បន្ននេះ យើងកំពុងធ្វើការប្រុងប្រយត្ន័បន្ថែមទៀតដោយលប់ចោលនូវៈ

- កម្មវិធីសាលាធំៗនៅក្នុងបរិវេណសាលារៀន
- កម្មវិធីសិក្សានៅថ្ងៃសៅរ៍ទាំងអស់ ( លើកលែងតែថ្នាក់រៀនយកក្រេឌិត “for credit” ) និងថ្នាក់ “Super Saturday” លើទីធ្លារសាលា
- កម្មវិធីហ្វឹកហ្វឺនបុគ្គលិកទាំងអស់ដែលតម្រូវឱយបុគ្គលិកធ្វើដំណើរចេញក្រៅសាលា
- ការប្រជុំមាតាបិតានិងសហគមន៍ទាំងអស់ដែលមិនសំខាន់

ថែមពីនោះទៀត យើងកំពុងតែលប់ចោលនូវការប្រើប្រាសសាលារៀនដោយអង្គការក្រៅសាលាផ្សេងៗផងដែរ។

កម្មវិធីប្រកួតកីឡានឹងប្រព្រឹត្តធ្វើទៅដោយមានតែអ្នកប្រកួតនឹងបុគ្គលិកចាំបាច់ ហើយពុំមានទសនិកជនទេ។

យើងដឹងថាលោកអ្នកជាច្រើនមានការបារម្មណ៍អំពីរឿងនេះ ហើយយើងកំពុងធ្វើការដោយពុំខ្លាចនឿយហត់ដើម្បីបញ្ជាក់នូវសុវត្ថិភាពនិងសុខភាពល្អដល់សិស្សយើងរាល់គ្នា។

ដោយសេចក្តីស្មោះស្ម័គ្រ,
Chris គ្រិស

គ្រិសស្តូហ្វើ ស្តាញហោហ្វើ
អគ្គនាយកនៃសាលាលរៀន